International Labour Organization

better factories Cambodia

# ការបណ្តុះបណ្តាលសំរាប់ការកែលំអការអនុវត្តន៍ការងារ ព័ត៌មានលំអិតរបស់កម្មវិធីឆ្នាំ ២០០៩

## ១. គោលបំណង

ដើម្បីសំរេចឱ្យបានសេណារីយ៉ូឈ្នះ-ឈ្នះ សំរាប់និយោជក និង កម្មករនិយោជិត តាមរយៈការកែលំអលក្ខខណ្ឌការងារ និង ការអនុវត្តន៏ការងាររបស់រោងចក្រ ។

## ២. សកម្មភាពបណ្តុះបណ្តាលកែលំអរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*

សកម្មភាពបណ្តុះបណ្តាលរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ជាកម្មវិធីបន្ថែមលើការពិនិត្យឃ្លាំមើល ដែលធ្វើឡើងដោយគំរោងនេះ ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ មានកម្មវិធីបណ្តុះណ្តាលគាំទ្រច្រើនប្រភេទដូចជា:

- ការបណ្តុះបណ្តាលបែបម៉ូឌុល ( ៧ ម៉ូឌុល ក្នុងរយៈពេល ១២ ខែ)
- ការបណ្តុះបណ្តាលផ្តោតលើបញ្ហាជាក់លាក់ណាមួយ ( ប្រធានបទ រួមមានៈ កិច្ចសហការនៅ កន្លែងការងារ សុវត្ថិភាពនិងសុខភាពការងារ (OSH) ការគ្រប់គ្រងធនធានមនុស្ស និង លក្ខខណ្ឌការងារ ការគ្រប់គ្រងម៉ោងធ្វើការប្រកបដោយប្រសិទ្ធិភាព ការបណ្តុះបណ្តាលសង្គ្រោះបឋម ជំនាញនៃការចរចា និង ការយល់ដឹងអំពីយែនឌ័រ)
- កម្មវិធីបណ្តុះបណ្តាលតាមរោងចក្រសំរាប់កម្មករ ( តាមរយៈការប្រើប្រាស់ខ្សែវីដេអូបែបជារឿង)
- ការបណ្តុះបណ្តាលកញ្ចប់ណែនាំការងារ (ខ្សែវីដេអូ សៀវភៅចីវចល និង សៀវភៅណែនាំសំរាប់អ្នកបណ្តុះបណ្តាល) សំរាប់អោយអ្នកគ្រប់គ្រងធនធានមនុស្ស ឬ គ្រូបណ្តុះបណ្តាលនៅតាមរោងចក្រប្រើប្រាស់ ។

វគ្គបណ្តុះបណ្តាលជំនាញសំរាប់មេការគឺដើម្បីអភិវឌ្ឍសមត្ថភាពរបស់មេការកម្មករ និង អ្នកគ្រប់គងជាន់ខ្ពស់ទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរ ។ ផែនការនៃវគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីធ្វើអោយប្រសើរឡើងទាំងទំនាក់ទំនងរវាងបុគ្គលិក និង អ្នកគ្រប់គ្រង និង ផលិតភាព ។ .

ចំនុចដែលជាសក្តានុពលបំផុតនោះគឺការបណ្តុះបណ្តាលបែបម៉ូឌុល ដែលមានរោងចក្រ ៧ ចូលរួម កំណត់ជា១ក្រុម ក្នុង ៧ ម៉ូឌុល ។

## ៣. ការបណ្តុះបណ្តាលបែបម៉ូឌុល

### ៣.១ គោលការណ៍

ការបណ្តុះបណ្តាលគួរ:

១. ដាក់បញ្ចូលទាំងមាតិកាស្នូល និង មាតិកា ដែលផ្អែកទៅលើអាទិភាពរបស់រោងចក្រដែលចូលរួម ។

២. មានការចូលរួមពីតំណាងអ្នកគ្រប់គ្រង និង តំណាងកម្មករ ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហការនៅកន្លែងការងារ ។

៣. ត្រូវមាននិរន្តរភាព និង កសាងសមត្ថភាពដល់អ្នកបណ្តុះបណ្តាលក្នុងស្រុក ដើម្បីអាចផ្តល់ការបណ្តុះបណ្តាល ដែលសមស្របក្នុងរយៈពេលវែង ។

៤. គាំទ្រដល់គោលដៅរបស់អង្គការពលកម្មអន្តរជាតិ ស្តីពីសមភាពយេនឌ័រ ។

៥. លើកទឹកចិត្តឱ្យមានការអនុវត្តន៍អ្វីដែលបានសិក្សា តាមរយៈការគាំទ្រនៅកំរិតរោងចក្រដល់ការអនុវត្តន៍ផែនការកែលំអរោងចក្រ (Factory Improvement Plans - FIPs) ។

៦. បង្កើតធនធាន និង ឯកសារនានា ដែលអាចចែករំលែកជាមួយនឹងឧស្សាហកម្មទាំងមូល ។

៧. ត្រូវផ្អែកលើគោលការណ៍សិក្សារបស់មនុស្សពេញវ័យ និង វិធីសាស្ត្រដែលមានការចូលរួម ។

៨. លើកទឹកចិត្តឱ្យមានបណ្តាញការងារ ការចែករំលែកបទពិសោធន៍ និង ការសិក្សាពីគ្នាទៅវិញទៅមក ដើម្បីធានាឱ្យមានការអនុវត្តន៍ល្អបំផុតនាពេលអនាគត ។

៩. គាំទ្រ និង លើកទឹកចិត្តឱ្យមានការកែលំអជាបន្ត ។

១០. មានប្រសិទ្ធិភាពលើការចំណាយ និង មានភាពប្រាកដនិយម ។

### ៣.២ មាតិកា

នឹងមានម៉ូឌុលចំនួន ៧ ដែលនឹងធ្វើឡើងប្រហែលជារៀងរាល់ ២ ខែក្នុង១ម៉ូឌុល ។ ម៉ូឌុលទាំងនេះរួមមាន:

១. បរិបទជាសកល (ម៉ូឌុលនេះចំណាយពេលតែ ១ ថ្ងៃប៉ុណ្ណោះ)

២. កិច្ចសហការនៅកន្លែងការងារ

៣. គុណភាព

៤. សុវត្ថិភាព និង សុខភាពការងារ

៥. ផលិតភាព

៦. ការគ្រប់គ្រងធនធានមនុស្ស និង លក្ខខណ្ឌការងារ

៧. ការកែលំអជាប្រចាំ (ម៉ូឌុលនេះចំណាយពេលតែ ១ ថ្ងៃប៉ុណ្ណោះ)

## ៣.៣ វិធីសាស្ត្រ

ការបណ្ដុះបណ្ដាលនេះនឹងផ្អែកលើគោលការណ៍នៃការសិក្សារបស់មនុស្សពេញវ័យ និង គោលការណ៍បណ្ដុះបណ្ដាលដែលផ្អែកលើសកម្មភាព។ ការអនុវត្តន៍នៅកំរិតរោងចក្រគឺជាអាទិភាព។ វិធីសាស្ត្រមាន បញ្ចូលៈ

- សិក្ខាសាលាបណ្ដុះបណ្ដាលចំនួន ២ ថ្ងៃ លើប្រធានបទដែលបានជ្រើសរើស ដោយមានការប្រើប្រាស់វិធីសាស្ត្របណ្ដុះបណ្ដាលដែលមានការចូលរួម។
- បន្ទាប់ពីសិក្ខាសាលា មន្ត្រីអង្គភាពកែលំអរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ និង គ្រូបណ្ដុះបណ្ដាលមកពី VBNK នឹងចុះពិនិត្យរោងចក្រនីមួយៗចំនួន ២ ដង (លើកទី ១ ពីរបីថ្ងៃក្រោយពីសិក្ខាសាលាភ្លាម និង លើកទី ២ ប្រហែលជា ២ ឬ ៣ សប្ដាហ៍ក្រោយមកទៀត) បន្ទាប់ពីម៉ូឌុលនីមួយៗ។ តួនាទីរបស់ពួកគេនឹងជួយដល់សិក្ខាកាមដែលបានចូលរួមក្នុងការបណ្ដុះបណ្ដាលឱ្យផ្ទេរព័តិមានទៅឱ្យគណកម្មាធិការប្រឹក្សាការកែលំអរោងចក្រ (PICC) និង ជួយពួកគេក្នុងការបង្កើតផែនការកែលំអរោងចក្រ (FIP)។
- ផែនការកែលំអរោងចក្រគួរត្រូវបានរៀបចំឡើងដោយ និង ជារបស់រោងចក្រផ្ទាល់។ ផែនការនេះគួរមានគោលដៅដែលមានភាពប្រាកដនិយមលើការអនុវត្តន៏ការកែលំអសំរាប់ម៉ូឌុលនីមួយៗ ដូចនេះវាត្រូវមានព្រំដែនកំរិតច្បាស់លាស់។
- មន្ត្រីអង្គភាពកែលំអរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ នឹងបន្តគាំទ្រ និង តាមដានការអនុវត្តន៏ផែនការនេះ។
- ប្រហែលជា ៦ សប្ដាហ៍ បន្ទាប់ពីម៉ូឌុលដំបូង នឹងមានសិក្ខាសាលារយៈពេលកន្លះថ្ងៃមួយទៀតសំរាប់ម៉ូឌូលនីមួយៗ។ សិក្ខាសាលានេះនឹងផ្ដល់ឱកាសឱ្យមានការចែករំលែកគំនិតស្ដីពីជោគជ័យ និង បញ្ហាប្រឈមមុខនានាក្នុងការអនុវត្តន៏អ្វីដែលបានសិក្សារួចមកហើយនៅកន្លែងការងារ។

នៅពេលដែលម៉ូឌុល និង ប្រធានបទ ត្រូវបានរៀបចំរួចរាល់ហើយ សេចក្តីលំអិតនៃការបណ្តុះបណ្តាលត្រូវមានភាពបត់បែន ដើម្បីសំរបទៅតាមកាលៈទេសៈពេលចាំបាច់ នៅពេលដែលកម្មវិធីមានការអភិវឌ្ឍន៍។ ដូចនេះ កម្មវិធីនេះនឹងប្រើប្រាស់វិធីសាស្ត្រ "រចនា និង សាងសង់" ដែលនៅក្នុងនោះការរចនាលំអិតរបស់ម៉ូឌុលនិមួយៗអាចកែតម្រូវបាន និង ប្រែប្រួលទៅតាមលទ្ធផលរបស់គំរោងដែលលេចឡើង។

## ៣.៤ ***ការចូលរួមក្នុងកម្មវិធី***

### *រោងចក្រដែលបានចូលរួម*

មានរោងចក្រចូលរួមចំនួន ៧ ដែលចែកចេញជា ១ ក្រុម។

សមាជិកភាពរោងចក្ររបស់ក្រុមនីមួយៗ នឹងមិនផ្លាស់ប្តូរឡើយ។ រោងចក្រចូលរួមនីមួយៗត្រូវចុះហត្ថលេខាលើ MOU ដែលមានចែងពីការប្តេជ្ញាចិត្ត និង ការទទួលខុសត្រូវរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ VBNK និង រោងចក្រទាំងនោះ។

រោងចក្រដែលចូលរួមនីមួយៗត្រូវបំពេញ "អាំងឌីកាទ័រ" ប្រចាំខែ លើប្រធានបទនីមួយៗ ដែលជាឧបករណ៍មួយ ដើម្បីតានដានរកផលប៉ះពាល់នានា ដែលកម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលនេះមានមកលើគំនិតផ្តួចផ្តើមកែលំអរបស់រោងចក្រនីមួយៗ។

### *អ្នកចូលរួម*

រោងចក្រនីមួយៗមានសិទ្ធិចាត់អ្នកចូលរួមក្នុងសិក្ខាសាលាចំនួន ៤ នាក់ - ២ នាក់ មកពីតំណាងអ្នកគ្រប់គ្រង និង ២ នាក់ទៀតមកពីតំណាងកម្មករ។ មានន័យថា អ្នកចូលរួមសរុបនឹងមានចំនួន ៥៦ នាក់ (អ្នកចូលរួម ២៨ នាក់) ដែលនឹងត្រូវចូលរួមផ្ទាល់ នៅក្នុងជុំនីមួយៗរបស់ការបណ្តុះបណ្តាល។

តំណាងកម្មករត្រូវតែងតាំងដោយសហជីពដែលពាក់ព័ន្ធ និង ជាទូទៅត្រូវមានប្រធានសហជីព និងអនុប្រធានសហជីព។

តំណាងកម្មករ និង យ៉ាងហោចណាស់តំណាងអ្នកគ្រប់គ្រងម្នាក់ ជាអ្នកចូលរួមសិក្ខាសាលាជាអចិន្ត្រៃយ៍។ ចំណែកតំណាងអ្នកគ្រប់គ្រងម្នាក់ទៀតអាចប្រែប្រួលទៅតាមប្រធានបទនៃសិក្ខាសាលា។

យ៉ាងហោចណាស់ពាក់កណ្តាលអ្នកចូលរួមជាស្ត្រី ។

រោងចក្រចូលរួមត្រូវទទួលខុសត្រូវធានាថាគ្រប់អ្នកចូលរួមទាំងអស់ (រួមទាំងតំណាងសហជីព/កម្មករ) នឹងត្រូវបានផ្តល់ឱ្យនូវមធ្យោបាយធ្វើដំណើរទៅ និង មកពីទីកន្លែងបណ្តុះបណ្តាល និង ផលប្រយោជន៍ដទៃទៀត)។

## *អ្នកទទួលខុសត្រូវ*

រោងចក្រត្រូវតែងតាំងមនុស្សម្នាក់ឱ្យទទួលខុសត្រូវសំរាប់ការអនុវត្តនីផែនការកែលំអរោងចក្រ និង មានតួនាទីជាអ្នកទំនាក់ទំនងសំរាប់មន្ត្រី *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ។

## *គណៈកម្មាធិការប្រឹក្សាការកែលំអរោងចក្រ*

រោងចក្រចូលរួមនីមួយៗត្រូវបង្កើតគណៈកម្មាធិការប្រឹក្សាការកែលំអរោងចក្រ (Performance Improvement Consultative Committee - PICC) ដែលមានគ្នាពី ៨-១០នាក់ ហើយ ដែលមានសមាសភាពស្មើគ្នាពីខាងអ្នកគ្រប់គ្រង និង តំណាងកម្មករដែលត្រូវបានទទួលស្គាល់។ គណៈកម្មាធិការនេះត្រូវដឹកនាំដោយនាយកចាត់ការទូទៅ ឬ អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀត។ សហគ្រាស ត្រូវព្យាយាមធានាអោយបានច្បាស់ថាយ៉ាងហោចណាស់ពាក់កណ្តាលនៃសមាជិករបស់គណៈកម្មាធិការនេះជាស្ត្រី។ គណៈកម្មាធិការនេះនឹងជួបប្រជុំជាទៀងទាត់យ៉ាងហោចណាស់ជារៀងរាល់ខែ ដើម្បីពិភាក្សាពីវឌ្ឍនភាពក្រោមផែនការកែលំអរោងចក្រ (FIP) ដែលពាក់ព័ន្ធជាមួយនឹងការបណ្តុះបណ្តាល។

## *ការបង់ថ្លៃ*

រោងចក្រនីមួយៗត្រូវបង់ថ្លៃសរុប ២៥០០ ដុល្លាសហរដ្ឋអាមេរិកសំរាប់កម្មវិធីទាំងមូល។ ការបង់ថ្លៃនេះគ្របដណ្តប់លើការចំណាយធំៗរបស់ VBNK ប្រសិនបើស្ថាប័ននេះរៀបចំកម្មវិធីបណ្តុះបណ្តាលដោយឯករាជ្យខ្លួនឯង។

អង្គការពលកម្មអន្តរជាតិនឹងចំណាយលើ:

- អ្នកជំនាញការបច្ចេកទេសជាតិ និង អន្តរជាតិ ក្នុងរយៈពេលនៃការផ្ទេរជំនាញ
- ការសរសេរចងក្រងកញ្ចប់បណ្តុះបណ្តាល និង សៀវភៅណែនាំការបណ្តុះបណ្តាល
- ការបកប្រែឯកសារទៅជាភាសាខ្មែរ និង ចិន

- ការបកប្រែការបណ្តុះបណ្តាលក្នុងថ្នាក់រៀនទៅជាភាសាចិន អង់គ្លេស និង ខ្មែរ
- ការគាំទ្រទៅក៏រិតរោងចក្រពីក្រុមការងារកែលំអរោងចក្រកាត់ដេររបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។

នៅពេលអនាគតយ៉ាងវែង (ពីឆ្នាំ ២០០៨ តទៅ) រាល់ការចំណាយទាំងនេះ នឹងត្រូវដាក់បញ្ចូលជាការបង់ថ្លៃ មានន័យថា នឹងតំឡើងថ្លៃ ដើម្បីយកមកគ្រប់គ្រងការចំណាយជាក់ស្តែងរបស់អ្នកផ្តល់ការបណ្តុះបណ្តាលក្នុងស្រុក ។.

## ***៣.៥ ដៃគូបណ្តុះណ្តាល និង ការកសាងសមត្ថភាព***

គ្មានដៃគូបណ្តុះបណ្តាលណានៅក្នុងប្រទេសកម្ពុជា ដែលនាពេលបច្ចុប្បន្ននេះមានសមត្ថភាពផ្តល់ការបណ្តុះបណ្តាលដោយឯករាជ្យ លើកម្មវិធីជាម៉ូឌុលបែបនេះទេ ។ អង្គភាពបណ្តុះបណ្តាលផ្សេងគ្នាមានចំនុចខ្លាំងខុសៗគ្នា ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ បានជ្រើសរើសយក VBNK ជាដៃគូបណ្តុះបណ្តាលដែលសមស្របជាងគេ ហើយបានសហការជាមួយ VBNK នៅក្នុងឆ្នាំ ២០០៥ ដើម្បីផ្តល់ការបណ្តុះបណ្តាលសំរាប់រោងចក្រចូលរួមទាំង ២ ក្រុម ។ VBNK មានសមត្ថភាពខ្ពស់លើការងារបណ្តុះបណ្តាលជាពិសេសនោះ មានការយល់ដឹងយ៉ាងល្អិតល្អន់លើការកែសំរួល និង បរិបទកម្មឯកសារបណ្តុះបណ្តាលឱ្យពាក់ព័ន្ធទៅនឹងបរិកាសសិក្សានៅកម្ពុជា ។

VBNK មានជំនាញបច្ចេកទេសអភិវឌ្ឍអ្នកគ្រប់គ្រង និង បុគ្គលិកខ្លាំងក្លា ។ ជាមួយនឹង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ VBNK នឹងបន្តអភិវឌ្ឍជំនាញបច្ចេកទេសរបស់ខ្លួនដើម្បីធានាអោយបានច្បាស់ថា ពួកគេអាចអនុវត្តកម្មវិធីនេះដោយឯករាជ្យចាប់ពីឆ្នាំ ២០០៧ តទៅ ។ យុទ្ធសាស្ត្រ ដើម្បីសំរេចការងារនេះរួមមានៈ

- ការបង្កើតឱ្យមានក្រុមបណ្តុះបណ្តាលនៅក្នុង VBNK ដែលមានគ្រូបណ្តុះបណ្តាលជនជាតិខ្មែរ ២ នាក់ ។ យ៉ាងហោចណាស់ម្នាក់ក្នុងចំណោមគ្រូបណ្តុះបណ្តាល ទាំងនោះជាស្ត្រី ។

- រៀបចំជាដៃគូរវាងគ្រូបណ្តុះបណ្តាលរបស់ VBNK ជាមួយនឹងអង្គភាពកែលំអរោងចក្ររបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។
- ប្រើប្រាស់អ្នកជំនាញការបច្ចេកទេសដែលឧបត្ថម្ភដោយអង្គការពលកម្មអន្តរជាតិ ក្នុងរយៈពេលតែ ២ ឆ្នាំដំបូង ដោយសហការជាមួយនឹងគ្រូបណ្តុះបណ្តាលរបស់ VBNK ។ នេះមានសារៈសំខាន់ជាពិសេសសំរាប់ម៉ូឌុលដែលស្តីពីគុណភាព និង ផលិតភាព ។ នៅក្នុងម៉ូឌុលទាំងនេះ អ្នកជំនាញការបច្ចេកទេសនឹងរៀបចំឯកសារបណ្តុះបណ្តាល រួមគ្នាជាមួយនឹងគ្រូបណ្តុះបណ្តាលរបស់ VBNK គាំទ្រដល់ការបណ្តុះបណ្តាល និង ជួយដល់ការចុះពិនិត្យមើលរោងចក្រក្រោយពីសិក្ខាសាលា និង រៀបចំផែនការកែលំអរោងចក្រ ។
- VBNK នឹងព្យាយាមគ្រប់បែបយ៉ាងឱ្យបុគ្គលិកក្រៅពីក្រុមបណ្តុះបណ្តាលដែលបានចាត់តាំង ឱ្យបានចូលរួមចំណែកនៅក្នុងកម្មវិធីនេះ ។ នេះនឹងជួយពង្រឹងចំណេះដឹង ជំនាញ និង ឥរិយាបទ ដែលចាំបាច់ ដើម្បីអនុវត្តកម្មវិធីនេះឱ្យកាន់តែទូលំទូលាយថែមទៀតនៅក្នុងអង្គភាព ។ អ្នកគ្រប់គ្រងផ្នែកបណ្តុះបណ្តាលរបស់ VBNK នឹងត្រូវចូលរួមចំណែក ដើម្បីធានាគុណភាពរបស់កម្មវិធីទាំងមូល ។

## ៣.៦ ការអភិវឌ្ឍន៍ឯកសារដែលជាធនធាន

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ជាមួយនឹងការគាំទ្រពី VBNK នឹងរៀបចំកញ្ចប់បណ្តុះបណ្តាល និង សៀវភៅណែនាំការបណ្តុះបណ្តាលសំរាប់ម៉ូឌុលនីមួយៗ:

សៀវភៅណែនាំ នឹង:

- ផ្តល់ព័ត៌មានបច្ចេកទេស និង ឧទាហរណ៍ជាក់ស្តែងគ្រប់គ្រាន់ ដែលពាក់ព័ន្ធនឹងឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា ដើម្បីឱ្យសហគ្រាសអាចចាប់ផ្តើមដោយខ្លួនឯង នូវកម្មវិធីកែលំអលើចំនុចដែលពាក់ព័ន្ធ ។
- ផ្អែកលើឯកសារបណ្តុះបណ្តាលរបស់កម្មវិធីបណ្តុះបណ្តាលជាម៉ូឌុល និង បទពិសោធនិពីរោងចក្រដែលចូលរួមក្នុងការអនុវត្តន៍ផែនការកែលំអរបស់ពួកគេ ។ ទាំងនេះរួមមានរូបថត និង ករណីសិក្សា ដែលទទួលបានពីកម្មវិធីបណ្តុះបណ្តាល ។
- មានខ្លឹមសារប្រហែលជា ៤០ ទំព័រ ដែលសរសេរជាភាសាសាមញ្ញងាយយល់ និង ប្រើប្រាស់ដ្យាក្រាម និង រូបភាពនៅកន្លែងដែលអាចដាក់បាន ។
- ត្រូវបានរៀបរៀងឡើងជាភាសាចិន អង់គ្លេស និង ខ្មែរ ។

កញ្ចប់បណ្តុះបណ្តាលត្រូវបានផលិតឡើង ដើម្បីឱ្យគ្រូបណ្តុះបណ្តាលដទៃទៀតអាចយកវាទៅប្រើប្រាស់។ ឯកសារទាំងនេះរួមមាន កំនត់ត្រាមេរៀន ឯកសារចែកជូនទាំងអស់ ស្លាយ PowerPoint និង លំហាត់ការងារជាក្រុម។

គ្រប់ឯកសារទាំងអស់នឹង:

- មានវេយិទភាពខាងយេនឌ័រ និង គាំទ្រដល់គោលដៅសមភាពយេនឌ័ររបស់អង្គការពលកម្មអន្តរជាតិ
- សមស្របទៅនឹងកំរិតសមត្ថភាពរបស់អ្នកចូលរួម

## ៣.៧ ការបង្ហាញពីលទ្ធផលឈ្នះ-ឈ្នះ

កម្មវិធីនេះផ្តោតទៅលើការកែលំអការអនុវត្តន៏ការងាររបស់រោងចក្រចូលរួមនីមួយៗ ដោយផ្តោតជាពិសេសទៅលើចំនុចទាំងឡាយណា ដែលការបណ្តុះបណ្តាលនឹងត្រូវបានរំពឹងទុកថានឹងមានផលប៉ះពាល់ជាវិជ្ជមានដល់ការកែលំអការអនុវត្តន៏ការងារ ដើម្បីធានាអោយបានច្បាស់ថាយុទ្ធសាស្ត្រកែលំអជាបន្ត ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រោងចក្រដែលចូលរួមនីមួយៗ។